# ការសំភាសន៍របស់អ្នកមីង ស្រេង អិត

ក៖ អ្នកដែរសំភាសន៍ ជាងស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍ ស្រេង អិត

<u>ការសង្ខេបប្រវត្តិរបស់អ្នកមីង ស្រេង អិត</u>

អ្នកមីង ស្រេង អិត មានអាយុ47ឆ្នាំហើយ។អ្នកមីង ស្រេង អិត មានភេទស្រី អ្នកមីង ស្រេង អិត មានទីលំនៅបច្ចុប្បន្ននៅភូមិបាល្លាំង។

ក៖ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បី ទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ នឹងប្រវត្តិរបស់ដូចតាចឹងហាសមីង ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ចឹងតើមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខ៖ ព្រមតើ!

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មីងមួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី20 ខែ2 ឆ្នាំ2018 គឺសំភាសន៍នៅភូមិបាល្លាំងថ្មី ឃុំអោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចឹងសំមីមានឈ្មោះពេញនឹងឈ្មោះអីគេដែរមីង?

ខ៖ ឈ្មោះពេញយ៉ាងម៉េច?

ក៖ ឈ្មោះត្រកូលរបស់មីងនឹងហើយឈ្មោះមីងហាស?

ខ៖ ឈ្មោះត្រកូលនឹងស្រេង អិត

ក៖  ឈ្មោះស្រេង អិត ចុះមានឈ្មោះហៅក្រៅទេមមីង?

ខ៖  មានតើ!

ក៖  ឈ្មោះហៅក្រៅឈ្មោះអីគេដែរមីង?

ខ៖  ឈ្មោះហៅក្រៅឈ្មោះចឹងហាស ដល់ពេលឈ្មោះក្នុងបញ្ជីជាតិឈ្មោះ ស្រី

ក៖  ចុះកាលពីក្មេងនឹងមាននរណាគេហៅឈ្មោះមីងអីផ្សេងពីនឹងទៀតទេមីង?

ខ៖  ពីក្មេងនឹងគេហៅផ្សេង ឈ្មោះក្នុងបញ្ជីជាតិនឹងផ្សេង រាល់ថ្ងៃដាក់តែឈ្មោះស្រេង អិតនឹងទៅ

ក៖  អូ៎!បាទ ចុះមីងសព្វថ្ងៃនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖  ខ្ញុំអាយុ47ឆ្នាំហើយ

ក៖  ចុះមីងមានចងចាំថ្ងៃខែឆ្នាំដែរមីងបានកើតទេ?

ខ៖  អត់ចងចាំទេ

ក៖  ប៉ុន្តែឆ្នាំក៏មីងមិនចាំដែរ?

ខ៖  ចាំតែឆ្នាំកោនឹង

ក៖  ឆ្នាំកោណមីង ចុះមីងអាយុប៉ុន្មាន47ឆ្នាំ ចឹងមីងកើតនៅឆ្នាំ1971

ខ៖  អើរនឹង

ក៖  ចុះមីងកើតនៅណាដែរមីង?

ខ៖  ម៉ែកើតនឹងមែនម៉ែកើតនៅបាល្លាំងនឹងមែន អើរថាកើតនៅបាល្លាំងនឹងទៅចាំព្រមមិនព្រមម៉េច

ក៖  ចឹងកើតនៅបាល្លាំង?

ខ៖ កើតនៅក្រោយបាល្លាំងនឹង

ក៖  ប៉ុន្តែកើតនៅភូមិអី ឃុំអីដែរមីង?

ខ៖  នៅភូមិដដែលនឹងភូមិបាល្លាំងនឹង

ក៖  អ៎ូ!នៅនឹងហោសមីង?

ខ៖  នៅនឹងតើ!

ក៖  ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖  មាន5នាក់

ក៖  មីងជាកូនទីប៉ុន្មានដែរមីង?

ខ៖  ជាកូនទី3

ក៖  ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរមីង?

ខ៖   ស្រីតែមួយនឹង

ក៖  ចឹងមានប្រុស4នាក់ស្រីតែមីងទេ?

ខ៖  នឹងហើយស្រីមួយ ប្រុស4នាក់

ក៖  ចុះមីងអាចប្រាប់ឈ្មោះបងប្អូនរបស់មីងបានទេ?

ខ៖  ប្រាប់បានតើ!

ក៖  គាត់មានឈ្មោះអីគេខ្លះដែរមីង?

ខ៖  ឈ្មោះស្រេង គីម ស្រ៊ុន , ស្រេង គីម ស្រៀវ

ក៖  ពួកគាត់ជាបងរបស់មីង?

ខ៖  នឹងហើយ

ក៖  ចុះប្អូនៗរបស់មីងវិញ?

ខ៖  ប្អូននឹងឈ្មោះ គីម តេង , ឈ្មោះគីម ទូច

ក៖  អ៎ូ!បាទមីង ចុះមិងមានចងចាំអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេមីង?

ខ៖  ចាំដែរតើ!

កៈ ដូចជាមីងមានលេងអីជាមួយគាត់ដូចជាលេងឡឹកបាយឡ
លេងបិទពួនអីចឹងហាសមីង?

ខៈ ទេក្មេងណុងគ្មានដៃរចេះលេងបិទពួនផងនឹង

កៈ មីងលេងអីគេចឹងមីង?

ខៈ កាលណុងដូចជាគ្មានចេះលេងឡឹកឡណាណីទេ ចេះតែដើរលេងរត់លេង
លោតអន្ទាក់អីនឹង

កៈ អូ៎!ចឹងទេ?

ខៈ ចេះតែលោតអន្ទាក់ លោតមឹកលោតឈូសនឹង មានជាន់មុងជាន់អីនឹង

កៈ នឹងជាអ្វីដែរជាមីងលេងជាមួយប្អូនរបស់មីង?

ខៈ នឹងលេងជាមួយប្អូននឹងប្អូនមិនជាអ្នករពិសប៉ុន្មានដៃរនឹង

កៈ អូ៎!បាទ
ចុះមីងគិតថាមីងចូលចិត្តលេងអីគេជាមួយបងប្អូនរបស់មីងកាលពីនៅក្មេងដៃរ?

ខៈ កាលណុងដូចជាមិនចូលចិត្តលេងអីទេ
កាលណុងដូចថាជាមួយប្អូនៗនឹងដូចថាវាមិនរពិសទេ
បើវារពិសនឹងគ្រាន់តែពរវាដើរលេងនឹងចឹងទៅ
គ្មានដៃរទៅលេងអីទេវានៅតូចៗពេកវាមិនបីពីរអីដូចគេ ណាវា15ឆ្នាំបានមានទៀត

កៈ អូ៎!វាយូរដៃរហោសមីង?

ខៈ វាយូរៗដៃរនឹង តាំងពីដាច់អាពតនឹងវាទើបតែមានម្តងទៀតឡូតែមានបាន2ជាប់គ្នា
ដល់ចឹងវានៅតូចៗនឹង

កៈ ចឹងមីងធំហើយណាមីង?

ខៈ យើងឡើងធំយើងឡើងចាស់ហើយនឹង
យើងឡើងធំឡើងអាយុជិត20ឆ្នាំហើយវាអាយុ17-18ឆ្នាំទៅ ហើយនឹង

កៈ ចឹងមីងស្រួលមើលគាត់ហើយណាមីង?

ខ៖ វាទើបអាយុបាន4-5ឆ្នាំនឹងបានពីរទៅបីឆ្នាំម្នាក់ៗនឹង

ក៖ បាទមីង ចុះមីងបងប្អូនរបស់មីងសព្វថ្ងៃគាត់រស់នៅណាខ្លះដែរមីង?

ខ៖ នៅកូរ៉េពីរនាក់

ក៖ បងប្អូនហាសមីង?

ខ៖ ប្អូនក្រៅពីនឹងគ្មាននៅកូរ៉េទេនៅខ្មែរទាំងអស់នឹង

ក៖ អូ៎!គាត់.........?

ខ៖ មាន3នាក់នៅខ្មែរ ហើយអា2នាក់ទៀតទៅកូរ៉េ

ក៖ ប៉ុន្តែពួកគាត់ធ្វើអីគេដែរមីង?

ខ៖ ពីណាគេ?

ក៖ បងប្អូនរបស់មីងហាស?

ខ៖ បងប្អូនរបស់មីងនឹងធ្វើស្រែចំការនឹង

ក៖ ចុះបងប្អូនរបស់មីងនៅកូរ៉េនឹងពួកគាត់ធ្វើអីគេដែរមីង?

ខ៖ មិនដឹងគេធ្វើអីផង ធ្វើរោងចក្រហី

ក៖ ធ្វើជាពលកររហោសមីង?

ខ៖ ធ្វើជាពលករនឹង

ក៖ អូ៎!ភាគច្រើនគេធ្វើការនៅក្នុងងរោងចក្រ នឹងធ្វើជាកសិកម្មមីង?

ខ៖ អើរ ប្រហែលជាធ្វើរោងចក្រហើយ

ក៖ ចុះម្តាយរបស់មីងមានឈ្មោះអីគេដែរមីង?

ខ៖ ឈ្មោះនាង

ក៖ ចុះឈ្មោះពេញរបស់គាត់មានឈ្មោះអីគេដែរមីង?

ខ៖ ឈ្មោះ ស នាង

កៈ ចុះមានដឹងថាគាត់ឥឡូវនឹងគាត់អាយុប៉ុន្មានដែរទេមីង?

ខៈ គាត់អាយុ70ឆ្នាំហើយ

កៈ គាត់អាយុ70ឆ្នាំគត់ហោសមីង?

ខៈ គាត់ចិតជាងទៀតហោស

កៈ គាត់អាយុចិតប៉ុន្មនដែរទៅមីង?

ខៈ ម៉ែអាយុចិប៉ុន្មានដែរម៉ែ?

កៈ យាយឥឡូវនឹងអាយុប៉ុន្មានដែរយាយ?

ខៈ អាយុ75ឆ្នាំ

កៈ អូ៎!យាយអាយុ75ឆ្នាំ ចឹងយាយកើតនៅឆ្នាំ1943 ចុះយាយកើតនៅណាដែរមីង?

ខៈ មិនដឹងអីផងមិនសួរគាត់ អត់ដឹងថាគាត់នៅណាដែរ
មិនដឹងគាត់កើតនៅស្រុកណាដែរនឹងប៉ុន្តែមក បានកូននៅនឹង

កៈ អូ៎!ចឹងហោស?

ខៈ នៅស្រុកនឹងដដែលនឹងហោស

កៈ ចុះឪពុករបស់មីងមានឈ្មោះអីគេដែរមីង?

ខៈ ឈ្មោះគាត់ស្លាប់បាត់ហើយមិនដឹងជានិយាយធ្វើអីទេអ្វីបោះចោលទៅ

កៈ អត់ទេគ្រាន់តែចង់ដឹងពីប្រវត្តិរបស់គាត់ហាស
ចឹងចង់ដឹងថាគាត់មានឈ្មោះអីគេចឹងហាស?

ខៈ គាត់ឈ្មោះស៊ិន ស្រេង

កៈ គាត់យាយហើយនឹងតាបងប្អូនគ្នាប៉ុន្មានឆ្នាំដែរមីង?

ខៈ តានឹងអាយុ72ឆ្នាំកាលពីគាត់ស្លាប់នឹង
ឥឡូវនឹងគាត់ស្លាប់បានប្រហែលជា4ឆ្នាំហើយនឹង

កៈ ចឹងមានន័យថាគាត់ប្រហែលជាអាយុ76-77ឆ្នាំហើយចឹង?

ខ៖  កាត់ដូចជាអាយុ76ឆ្នាំហើយហី
កាលពីកាត់ស្លាប់នឹងអាយុ72ឆ្នាំដល់ពេលឥឡូវនឹងបុណ្យខួបគាត់
រួច3ឆ្នាំហើយរហូតមកដល់ឆ្នាំនឹងទៀត

ក៖  ចឹងមានន័យថាគាត់អាយុ76ឆ្នាំ?

ខ៖  គាត់អាយុ76ឆ្នាំនឹង

ក៖  ចុះតាគាត់កើតនៅណាដែរមីង?

ខ៖  គាត់កើតនៅនឹងដែរនៅភូមិគាត់នៅកន្លែងនឹង ស្រុកគាត់នៅនឹងតើ!

ក៖  បាទមីង ចុះតាកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខ៖  គាត់ចិញ្ចឹមគោ ចិញ្ចឹមអីនឹង គាត់ជាកសិករដាំបន្លែអីនឹង
គាត់អ្នកចំការមានធ្វើអីមានតែធ្វើស្រែធ្វើ ចំការដាំបន្លែដាំត្រកួនទៅ ដាំស្ពៃចឹងទៅ
ដាំចេកទៅចឹងទៅណាស់ចិញ្ចឹមកូនចិញ្ចឹមចៅនឹង គាត់ចិញ្ចឹមគោទៅ

ក៖  ចុះគាត់ស្លូតរឺមួយក៏កាចដែរមីង?

ខ៖  ថាគាត់កាចក៏ថាបានដែរ
ថាគាត់ស្លូតក៏ថាបានដែរនិយាយរួមទៅនៅស្រុកភូមិនឹងគេខ្លាចគាត់ ទាំងអស់នឹង

ក៖  អូ៎!ម៉េចចឹង?

ខ៖  គាត់អត់មាត់ទេប៉ុន្តែគាត់មាត់មួយម៉ាត់បានៗៗតែម្តងនឹង

ក៖  ប៉ុន្តែគាត់មិនមែនមេភូមិណាហីមីង?

ខ៖  អត់ទេគាត់ធម្មតាចឹងនឹង

ក៖  គាត់ធម្មតាហោសមីង?

ខ៖
ប៉ុន្តែពីក្មេងមកគាត់ធ្វើជាប្រធានភូមិដែរដល់ពេលដែរចាស់ទៅគេទំលាក់ឈប់អោយគាត់
ធ្វើអោយទៅ ក្មេងទៅ

ប៉ុន្តែលក្ខណៈថានៅក្នុងស្រុកក្នុងភូមិចឹងគាត់មិនសូវចេះនិយាយអីច្រើនទេតែគាត់និយាយមួយ ម៉ាត់ៗនឹងដឹងតែអ្នកស្រុកខ្លាចតែម្តងនឹង

កៈ ចុះម្តាយរបស់មីងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរកាលពីគាត់នៅក្មេង?

ខៈ កាលពីគាត់នៅក្មេងនឹងគាត់ជួយធ្វើការងារប្តីរបស់គាត់

កៈ អូ៎!គាត់ធ្វើស្រែធ្វើចំការទៅ?

ខៈ ធ្វើស្រែធ្វើចំការទៅឡើងត្នោតដែរនឹង

កៈ អូ៎!យាយឡើងត្នោតដែរ?

ខៈ នឹងហើយបើមិនឡើងណាចិញ្ចឹមកូនរស់នឹងចុះមាន5-6នាក់ទៅហើយនឹង

កៈ ចុះយាយស្លូតរឺមួយក៏កាចដែរមីង?

ខៈ យាយស្លូតនឹង

កៈ
ចុះមីងមានចងចាំថាកាលពីមីងនៅជាមួយយាយតាតើមីងធ្លាប់បានធ្វើអីគេខ្លះជាមួយពួកគាត់ទេ ដូចជាអនុស្សាវរីយ៍ហាស?

ខៈ អនុស្សាវរីយ៍នៅជាមួយមានតែធំមកពេលដែរដាច់អាពតមកមានតែជួយមើលប្អូននឹងគ្មានធ្វើអី

កៈ អូ៎!ចឹងទេ?

ខៈ ការងារមើលតែប្អូននឹងទៅរៀនមានតែប៉ុណ្ណឹង

កៈ ចុះយាយតាខាងម្តាយមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ខាងម្តាយក្មេកហោស?

កៈ អត់ទេខាងម្តាយរបស់មីងហាស ឪពុកម្តាយរបស់មីងហាស?

ខៈ នឹងឈ្មោះសូន្យ នាង នឹង ឈ្មោះសូន្យ ស្រេងនឹង

កៈ នឹងខាងម្តាយណាមីង?

ខ៖ នឹងតាកយង យាយ វ៉ន ស្អីទេខ្ញុំភ្លេចឈ្មោះបាត់ហើយនឹង

ក៖ ចុះយាយតាខាងឪពុកវិញមីង?

ខ៖ នៅក្នុងណុងកត់នៅក្នុងណុងឈ្មោះគាត់នឹងហាស

ក៖ អូ៎!ចុះមីង?

ខ៖ ដាក់ត្រកូលគាត់ឈ្មោះស្រេង ឈ្មោះសូន្យ ស្រេងចឹង

ក៖ ឈ្មោះសូន្យ ស្រេងហោសមីង?

ខ៖ នឹងហើយ

ក៖ ម្តាយរបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិយាយតាទៅមីងដែរទេ?

ខ៖ គាត់មានប្រាប់ណាបើគាត់ស្លាប់នឹងតាំងពីឯងនៅតូចៗមកម្ល៉េសនឹង

ក៖ អូ៎!ចឹង?

ខ៖ បានអីដឹងបើឯងទើបតែចេះដើរនឹង ចេះដើរចេះរត់តាមហើយនឹង

ក៖ អូ៎!បាទ?

ខ៖ ចឹងគាត់ស្លាប់តាំងពីឯងនៅតូចៗមកចឹងប្រវត្តិគាត់យើងម៉េចដឹង

ក៖ ចុះដូចជាមីងមកនៅនឹងយូរនៅមីង?

ខ៖ នៅតាំងពីដាច់អាពតមកនៅនឹងរហូតនឹង

ក៖ តាំងពីដាច់អាពតមកចឹងមានន័យថាប្រហែលជាខ្ទង់ជាង40ឆ្នាំហើយចឹង ជិត40ឆ្នាំហើយនឹង?

ខ៖ ពេលដែរដាច់មកនឹងមកនៅវាលខ្សាច់ហោស

ក៖ នៅវាលខ្សាច់?

ខ៖ ដល់ពេលរួចបានរត់មកនៅនឹងមកនៅពីរកន្លែង

កៈ មីងអាចសុំនិយាយអោយលឺតិចបានទេមីង ដោយសារតែខ្ញុំរីខតសំលេងចឹងចង់អោយយើងនិយាយ លឺទាំងងស់គ្នាចឹងហាសមីង?

ខៈ នឹងហើយនិយាយលឺប៉ុណ្ណឹងលឺអត់?

កៈ មីងអាចសំលេងលឺជាងនឹងតិចកាន់តែល្អ?

ខៈ និយាយកុំអោយលឺពេក

កៈ ចុះមីងមានបងប្អូនរឺមួយក៏សាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសទេមីង?

ខៈ អត់មានទេ

កៈ ប៉ុន្តែមិញនឹងមីងមានប្អូនហី?

ខៈ មានតែប្អូន2នាក់នឹង

កៈ រស់នៅកូរ៉េហីមីង?

ខៈ នឹងហើយនៅកូរ៉េ

កៈ ចុះមានអ្នកថៃ នៅវៀតណាម នៅជប៉ុនអីមានទេ?

ខៈ មានតែក្មួយៗនឹង

កៈ ប៉ុន្តែពួកគាត់នៅណាដែរមីង?

ខៈ មិនទាន់មានប្រពន្ធកូនផង

កៈ ប៉ុន្តែពួកគាត់នៅណាដែរមីង?

ខៈ ពួកគាត់នៅឆ្ងាយៗដែរនឹងនៅថ្មគោលនឹង

កៈ អត់ទេចង់និយាយថាអ្នកដែររស់នៅក្រៅប្រទេសហាសមានទេមីង?

ខៈ អត់មានទេ

កៈ អត់មានទេណាមីង?

ខៈ នៅក្រៅប្រទេសនឹងមានតែប្អូនទៅធ្វើពលករនៅកូរ៉េនឹង

កះ  ចុះស្វាមីរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខះ  ឈ្មោះរុណា រ៉េន

កះ  ចុះមីងមានចងចាំថ្ងៃដែរមីងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេមីង?

ខះ  កាលណាទេរាប់ទៅការតាំងពីអាយុ19ឆ្នាំ

កះ  និយាយរួមកូនបងរបស់មីងនឹងអាយុប៉ុន្មានដែរឥឡូវនឹង?

ខះ  អាយុ26ឆ្នាំហើយនឹង

កះ  ចុះអាយុ26ឆ្នាំចឹងមីងគិតថាពេលដែរមីងការហើយនឹងមីងនៅទំនេរពោះរឺមួយក៏មានកូនតែម្តង?

ខះ  ខ្ញុំទំនេរបានមួយឆ្នាំ

កះ  ចឹងមានន័យថាមីងការនឹងអស់ប្រហែលជា28ឆ្នាំហើយដោយសារតែមីងទំនេរពោះមួយឆ្នាំ?

ខះ  កូនអាយុ26ឆ្នាំហើយ

កះ  កូនរបស់មីងអាយុ26ឆ្នាំប៉ុន្តែមីងទំនេរពោះមួយឆ្នាំចឹងមានន័យថាមីងការអស់28ឆ្នាំ?

ខះ  នឹងហើយ

កះ  ចុះពេលដែរមីងរៀបអាពាហ៍ពិពាហ៍នឹងដូចជាមីងជាង្អករៀបដំដោយចិត្តឯងរឺមួយក៏ម្តាយឪពុកជា អ្នករៀបចំអោយដែរ?

ខះ  ឪពុកម្តាយ

កះ  ចុះដូចជាមានជាជំនូនទេមីងពេលណុង?

ខះ  មានតើ!

កះ ប៉ុន្តែដូចជាប៉ុន្មានដែរមីងអាចប្រាប់បានទេ?

ខះ  ប៉ុន្តែចង់និយាយថាជំនូនកាលណុង30ម៉ឺននឹង

កះ  បាន30ម៉ឺនលុយខ្មែរយើងណមីង?

ខ៖ នឹងហើយ

ក៖ ចុះមីងមានចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខ៖ សរសេរបានត្រឹមតែថ្នាក់ទី3នឹងរៀនមិនសឹងទាំងចប់ថ្នាក់ទី3ផងនឹង

ក៖ អូ!កាលពីមីងរៀននឹងតើមីងរៀននៅណាដែរមីង?

ខ៖ រៀននៅសាលាថ្មគោល

ក៖ រៀននៅថ្មគោលរៀននៅសាលាបឋមសិក្សាថ្មគោលណាមីង?

ខ៖ នឹងហើយ

ក៖ ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរទេមីង?

ខ៖ ចេះភាសាខ្មែរយ៉ាងម៉េចបើឥឡូវនឹងងងឹតសរសេរភាសាខ្មែរមិនកើតផងនឹង ពីមុនយើងសរសេរកើត
ដល់ពេលឥឡូវនឹងអាយុជាង40ឆ្នាំនឹងអោយតែសរសេរអក្សរព្រិលតែម្តងនឹង

ក៖ ប៉ុន្តែចង់និយាយថាភាសាអីក្រៅពីភាសាខ្មែរដូចជាភាសាចិន ថៃ វៀតណាមអីបារាំងអីនឹងមីង?

ខ៖ គ្មានចេះអីបើមិនដែរបានដើរទៅណាផងនឹងនៅតែផ្ទះនឹង

ក៖ អូ!បាទមីង?

ខ៖ ប្អូនតើវាដើរបានឆ្ងាយៗនឹង

ក៖ ចុះមីងមានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាទេមីង
ធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលធំធាត់មកជាមួយគ្នា ដែរទេមីង?

ខ៖ មិត្តភក្តិពេលដែរឥឡូវៗនឹងហោស?

ក៖ អត់ទេតាំងពីក្មេងហាស?

ខ៖ តាំងពីក្មេងមិនដែរមានមិត្តភក្តិនឹងគេទេ មិនចេះមានមិត្តភក្តិនឹងគេទេ

ក៖ អូ!មិត្តភក្តិនៅរៀនអីក៏មិនមានដែរ?

ខ៖  មានតែបងប្អូនឯងៗដែរស្គាល់ៗនឹងទៅមិនមានមិត្តភក្តិផង
មិនដែរទៅណាទៅណីទេអត់ចេះមានទេ

ក៖  ជាមួយបងប្អូនបង្កើតរឺមួយក៏ជាមួយបងប្អូនជីដូបមួយអីមីង?

ខ៖  ជាមួយបងប្អូនជីដូនមួយនឹងក្រៅពីនឹងគ្មានទេ

ក៖  ចុះកាលពីក្មេងៗនឹងមីងធ្លាប់បានធ្វើអីគេខ្លះជាមួយពួកគាត់ដែរមីង
លក្ខណះអនុស្សាវរីយ៍អីជាមួយ ពួកគាត់ហាស?

ខ៖  ទៅធ្វើចំការជាមួយគ្នាគ្មានធ្វើអីទេ ចេញពីរៀនមកនាំគ្នាទៅដងទឹកនៅក្នុងអណ្តូងទៅ
នាំគ្នាទៅបុកអង្ករដាំបាយចឹងទៅដើរបុកអង្ករទៅ ទៅរកអូសទៅធ្វើតែចឹង

ក៖  អូ៎!បាទមីងចេះមីងមានធ្លាប់ទៅធ្វើស្រែចំការទេមីង?

ខ៖  អត់ទេ

ក៖  ស្រែនឹងចំការមីងមិនដែរទៅធ្វើទេណាមីង?

ខ៖  អត់ដែរទេបើម្តាយអោយនៅមើលផ្ទះចាំប្អូននឹង

ក៖  អូ៎!ចឹងបាទ?

ខ៖  គ្មានទៅណារួចទៅចុះនៅតូចៗនឹង

ក៖  ចុះមីងមានធ្លាប់លក់ដូរអាជីវកម្មអីនៅក្នុងក្រុមគ្រួសារអីទេមីង?

ខ៖  លក់តើ!

ក៖  មីងលក់អីគេដែរទៅ?

ខ៖  លក់ត្រកួន លក់ឈូស

ក៖  អូ៎!ទៅរកខ្លួនឯងណាមីង?

ខ៖  ទៅរកខ្លួនឯងនឹង

ក៖  យើងទៅរកនៅបឹងមែនទេមីង?

ខ៖  ទៅរកនៅបឹងនឹង

កៈ អូ៎!បាទមីង?

ខៈ ត្រកូនយើងដាំខ្លួនឯងទៅ ហើយឈូសនឹងយើងដាំទៅហើយទៅលក់ទៅ

កៈ យើងដាំនៅណាវិញមីង?

ខៈ ដាំនៅបឹងនឹង

កៈ បឹងនឹងលក្ខណៈថាគេអោយយើងដាំទាំងអស់គ្នារឺយ៉ាងម៉េចដែរមីង?

ខៈ អត់ទេចឹងយើងទិញគេអាជាប់ចឹងពីដើមមកជាដីរបស់គេចឹងយើងទិញគេ

កៈ អូ៎ចឹង?

ខៈ យើងទិញគេបើគ្មានដីទេយើងជួលគេធ្វើទៅ

កៈ ជួលគេគិតជាឆ្នាំអីចឹងហាសណាមីង?

ខៈ នឹងហើយគិតឆ្នាំគិតខែអីចឹង ហើយគិតមួយឆ្នាំៗចឹងទៅ

កៈ ប៉ុន្តែភាគច្រើនយើងចំណេញរឺមួយក៏ខាតដែរមីង
អាស្រ័យយើងមើលលើឆ្នាំដែរតើហីមីង?

ខៈ
ដល់ឆ្នាំណាចំណេញៗទៅដល់ឆ្នាំណាខាតនឹងខាតទៅនិយាយរួមទៅទើបតែពីរបីឆ្នាំនឹងទេ
ដែរខាត ហោស

កៈ រាល់ឆ្នាំចំណេញច្រើន?

ខៈ
រាល់ឆ្នាំបានចំណេញចិញ្ចឹមគ្រួសាររស់ទៅសល់បានទិញរបស់របរអីចឹងចំណេញៗបានទៅ
ណាស់

កៈ បាទមីង?

ខៈ ដល់ពេលពីរឆ្នាំនឹងដាក់ទៅរលាយហិនហោចអស់តែម្តងនឹង

កៈ ម៉េចចឹងមីងដោយសារតែអាកាសធាតុរឺមួយដោយសារតែអីគេដែរមីង?

ខ៖ ដោយសារតែអាកាសធាតុហើយមើលទៅ

ក៖ អូ!បាទមីង?

ខ៖ ដាំទៅអស់ទាំងដើម ដាំទៅខាតទាំងដើមខាតទាំងចុងទៅនឹង
ខាតអស់ធ្វើអស់50ម៉ឺនចឹងធ្វើបានតែ 20ម៉ឺនអីចឹងទៅ

ក៖ វាក្ដៅពេកហីមីង?

ខ៖ វាក្ដៅនឹង

ក៖ អូ!ពេលដែរវាក្ដៅចឹងទៅធ្វើអោយរលួយដំណាំអីចឹងទៅ?

ខ៖ ធ្វើអោយរលួយដំណាំនឹងណាស់
ឈប់ដាំឈប់អីទៅត្រកួនទិញដីគេអស់5ជីនឹងមិននឹងបានដើមមក វិញផងនឹង

ក៖ ប៉ុន្តែឥឡូវនឹងយើងឈប់ហើយមែនទេមីង?

ខ៖ ឈប់ហើយនឹងទុកចោលទៅ

ក៖ អូ!បាទមីងចុះមីងគិតថា.........?

ខ៖ យើងដាំដំណាំនៅលើគោកវិញទៅនឹង

ក៖ អូ!បាទមីង?

ខ៖ ដាំដំណាំចាស់

ក៖ មីងដាំអីគេដំណាំចាស់នឹង?

ខ៖ ដំណាំចាស់នឹងមានចេក ស្ពៃ

ក៖ ប៉ុន្តែមីងមានដីដាំខ្លួនឯងណាមីង?

ខ៖ មានដីខ្លួនឯងនឹង

ក៖ អូ!បាទ
ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតើមីងធ្លាប់ធ្វើការងារអីគេខ្លះដែរមីង?

ខ៖  គ្មានធ្វើអីទេមានតែធ្វើស្រែចំការបានទៅដាំទៅលក់
ទៅដូរនឹងគ្មានធ្វើអីទេយើងធ្វើតែចឹង

ក៖  អូ៎!បាទមីង?

ខ៖
គ្មានធ្វើការងារអីក្រៅពីធ្វើស្រែចំការបើយើងកូនអ្នកស្រែចំការនឹងដាំបានទៅទៅលក់ទៅ

ក៖
ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាសតើជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរមីង?

ខ៖  អូ៎!ផ្លាស់ប្តូរនឹងវារាប់មិនឈ្នះទេនិយាយពីផ្លាស់ប្តូរនឹង
ផ្លាស់ប្តូរឈឺទៅអីទៅគ្រាន់តែឈឺនឹង3-4-5ឆ្នាំ នឹងមិនបានធ្វើអីកើតផង

ក៖  បាទមីង?

ខ៖  គ្រាន់តែដេកឈឺនៅមើលផ្ទះគ្រូឡើងអស់5ឆ្នាំហើយមឹងគ្មានបានរកស៊ីអីផងនឹង

ក៖  ម៉េចបានយើងឈឺចឹងមីង?

ខ៖  ម៉េចដឹងមិនដឹងថាយើងកសាងពីជាតិមុននឹងទៅជាយ៉ាងណាដែរបានយើងឈឺនឹង

ក៖  អូ៎!ចឹង?

ខ៖ ចោរលួចគោទៅ ចោរលួចម៉ូតូទៅអីទៅសព្វគ្រប់សព្វបែបនឹងទាំងអស់នឹង
និយាយទៅជីវិតរបស់ខ្ញុំ នឹងវេទនាណាស់

ក៖  គេហៅរាសីហ៍ដាក់ហីមីង?

ខ៖
ដាក់នឹងជីវិតរបស់ខ្ញុំតាំពីខ្ញុំលើផ្ទះរួចបានមួយឆ្នាំនឹងជីវិតរបស់ខ្ញុំវេទនារហូតទាល់តែដល់សព្វថ្ងៃនឹង ហាស
ប៉ុន្តែសព្វថ្ងៃនឹងវាលែងពិបាកធូរចិត្តខ្លួនឯងត្រង់ថាខ្លួនឈឺដើររកមើលគេចឹងហាស

ក៖  ដោយសារតែមានកូនៗគាត់ធំហើយណាមីង?

ខ៖
ដោយសារតែបានកូនវាធំៗចឹងទៅវាទៅជួយរកម៉ែជួយទប់ចងដៃការគេនឹងបុណ្យគេចឹងទៅ យើងក៏វារៀងធូរបន្តិចដែរណាស់

ក៖ បាទមីង?

ខ៖ ពីមុនមកនឹងណាឈឺផងណា..........!

ក៖ កូនៗនៅតូចៗផងណាមីង?

ខ៖ កូនៗនៅតូចៗហើយវាទៅរៀនហោស

ក៖ ចឹងយើងត្រូវការចិញ្ចឹមពួកគាត់ច្រើន?

ខ៖ យើងត្រូវការចិញ្ចឹមពួកវាច្រើនទៀតនឹងចឹងវាមិនលំបាក

ក៖ បាទមីង?

ខ៖
ណាផ្ទះកាលណុងគ្មានម៉ែមកនៅជិតម៉ែមិនដែរមកនៅនឹងផងនឹងមកនៅនឹងទើបតែឪពុកស្លាប់ហើយនឹងនៅតែពីរនាក់ប្ដីប្រពន្ធនឹង ចិញ្ចឹមជ្រូកបិទស្រា

ក៖ ប៉ុន្តែនឹងកាលពីមីងនៅមានកូននៅតូចៗៗណាមីង?

ខ៖ កាលកូននៅតូចៗនឹង

ក៖ ចុះពីមុននឹងមីងរៀបអាពាហ៍ពិពាហ៍នឹងមីងមានការលំបាកអីផ្សេងទេមីង?

ខ៖
ពីមុននឹងអត់លំបាកផងនឹងពីព្រោះម៉ែឪនៅថែរក្សាចិញ្ចឹមយើងនឹងយើងនៅតែទៅរៀននឹង

ក៖
ដល់ពេលដែរមីងចាប់ផ្ដើមរៀបចំអាពាហ៍ពិពាហ៍រីការហើយនឹងមីងចាប់ផ្ដើមកសាងជីវិតខ្លួនឯងហើយណាមីង?

ខ៖
កសាងជីវិតខ្លួនឯងនឹងគ្រាន់តែការរួចបានតែមួយឆ្នាំនឹងហើយនឹងកូនចាប់បាន2ឆ្នាំប៉ានឹង

ម៉ែចេញ បែកពីយើងទៅយើងចាប់ផ្តើមយ៉ាប់រហូតហើយនឹង
ប៉ុន្តែយ៉ាប់នឹងយើងយ៉ាប់បានលុយណាស់

ក៖ បាទមិងបាទ?

ខ៖
យើងអត់ថាពិបាកទេពីព្រោះយើងយ៉ាប់ដែរប៉ុន្តែយើងរកបានចឹងយើងទិញនេះទិញនោះបាន យើងបានលើកផ្ទះលើកអីចឹង
យើងចាក់អណ្តូងបានទឹកផឹកអីចឹងយើងបានធូរដែរចឹងទៅណាស់

ក៖ បាទមីងនឹង?

ខ៖ ថាយើងអត់មានពិបាកទេមកពិបាកនឹងត្រង់យើងចាប់ផ្តើមឈឺ
ចាប់ផ្តើមត្រង់គេធ្វើបាបត្រង់ថាចិញ្ចឹម មាន់ ចិញ្ចឹមទាទៅគេលួចគេឆក់យកអស់ហើយនឹង

ក៖ ប៉ុន្តែពេលណុងមីងនៅតែជាមួយកូនទេណាមីង?

ខ៖ នៅតែជាមួយកូនទេនឹងនៅបិទស្រា
ចិញ្ចឹមជ្រូកនឹងមួយថ្ងៃៗនៅតែដួសទឹកពីរនាក់ប្តីប្រពន្ធចឹងទៅ
អាកូនវានៅតូចៗវាទៅរៀននឹងវាដើរលេងបាត់ៗចុះយើងមានតែពីរនាក់ប្តីប្រពន្ធនឹង

ក៖ បាទមីងបាទ?

ខ៖
យើងនៅធ្វើនៅនឹងទៅហើយបិទស្រានឹងមានដែរបានទំនេរណាបិទទល់ព្រលប់នឹងគ្មានដែរបានដេក ថ្ងៃណា

ក៖ ប៉ុន្តែឥឡូវនឹងមីងឈប់បិទហើយណាមីង?

ខ៖ ឈប់ហើយចាស់ហើយនឹងចុះសុំសិល្ប៍ហើយនឹង ខ្ញុំសុំសិល្ប៍អស់4ឆ្នាំហើយនឹង

ក៖ បាទមីង?

ខ៖ តាំងពីមុនឪពុកស្លាប់មកម្ល៉េសនឹង

ក៖ ចង់សួរមីងមួយដោយសារតែមីងនៅក្មេងៗនឹងមីងកើតទាន់ពលពតនឹងហាស
មីងមានបានធ្វើអីគេខ្លះដែរជីវិតរបស់មីង?

ខ៖
ថាពិបាកកាលពីជំនាន់ពលពតនឹងទោចំកន្លែងដែរគ្មានបាយស៊ីពិបាកខ្លួននឹងគ្មានសាច់ស៊ីទេ នៅសល់តែឆ្អឹងនឹង នៅសល់តែស្បែកហើយនឹងឆ្អឹងទេ

ក៖ ប៉ុន្តែពេលណុងមីងនៅកងកុមារទេណាមីង?

ខ៖ នៅកុមារគេគ្មានទាន់អោយយើងធ្វើអីគេអោយយើងនៅតែផ្ទះនឹង

ក៖ ប៉ុន្តែគ្រាន់ថារឿងដែរពិបាកនឹងគឺអត់បាយម្ហូប?

ខ៖ អត់បាយម្ហូប អត់បាយស៊ីបបរ5ចានមិនបានមួយស្លាបព្រាអង្ករផងនឹង

ក៖ អ៊ូ!ចឹង?

ខ៖ នៅមាន់ហើរនឹង

ក៖ អ៊ូ!ចឹងមីងនៅមាន់ហើរហោសមីង?

ខ៖
ណុងកាលជំនាន់ណុងជំនាន់អាពតនឹងនៅមាន់ហើរតើ!នឹងម្តាយមាននៅជិតណាឪពុកទៅឡើង ត្នោតនឹងម្តាយទៅលើកទំនប់នៅភ្នំហានិជ័យចឹងហី

ក៖ បាទមីង?

ខ៖ ណុងទៅលើកទំនុបកែប្រែណុងទៅលើកនៅណុង
រួចទៅនៅជាមួយម្តាយធំនៅទីនេះនឹងរូបថតនៅ ណុង

ក៖ បាទចឹងមីង?

ខ៖ ចុះកូនគាត់4-
5នាក់គាត់ថែឯងហោសចុះបើឯងនៅសល់តែស្បែកហើយនឹងឆ្អឹងនឹងជីវិតកន្លែងណុងវេទនាណាស់នៅតូចមែនប៉ុន្តែតូចមានមនុស្សចិញ្ចឹមមែនប៉ុន្តែពិបាក

ក៖ បាទមីង?

ខ៖ គិតថាខ្លួនឯងថាពិបាកមិនស្រួលទេ

ក៖ ប៉ុន្តែពេលណុងគ្រួសាររបស់មីងឪពុកម្តាយរបស់មីងនៅជាមួយគ្នាហោសមីង?

ខ៖ អត់ទេអត់នៅផងនៅបែកគ្នានឹង

ក៖ ពួកគាត់ទៅណាទៅមីង?

ខ៖ ពួកគាត់មួយឡើងត្នោត មួយទៀតទៅលើកដីនៅទំនុបកែប្រែនឹង

ក៖ ប៉ុន្តែនៅកន្លែងផ្សេងគ្នាទាំងអស់ហោសមីង?

ខ៖ នៅកន្លែងផ្សេងគ្នាទាំងអស់នឹង
ថានៅបែកខ្ញែកគ្នាទាំងអស់នឹងកាលនៅជំនាន់អាពតនឹង សូម្បីតែបងនោះក៏មិននៅដែរនឹង
ប៉ុន្តែអាពីរនឹងទៅកូរ៉េនឹងគេមិនទាន់កើតទេទាល់តែបែកពីអាពតមកវិញ នឹងណាស់

ក៖ បាទមីងបាទ?

ខ៖ ប៉ុន្តែពីរណុងនៅលើកអាចម៍គោគេកុមារទេណាស់ពេលណុង
គេអោយនៅលើកអាចម៍គោហើយ ពេលណុងហោសប៉ុនៗណុងនោះ
ចំណែកឯងនៅតូចទេគេមិនទាន់ប្រើឯងធ្វើអីទេ នៅយំតាមគេនៅឡើយទេនឹង

ក៖ ចុះមីងគិតថាមីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខ៖ លំបាកនឹងលំបាកវេទនាប្ដីនឹងតែម្ដងនឹងលំបាកខ្លាំងតែម្ដងនឹង

ក៖ ដូចជាពិបាកដោយសារតែគាត់ធ្វើបាបមីងរឺមួយក៏យ៉ាងម៉េចដែរ?

ខ៖ អត់មាននរណាគេធ្វើបាបទេដូចថាយើងពិបាកខ្លួនយើងដូចថាវា
រឿងប្ដីប្រពន្ធនឹងអត់មានបានធ្វើ បាបទេនឹងពិបាកដូចថា.........!

ក៖ ពិបាករកលុយអីនឹងហោសមីង?

ខ៖ ពិបាករកលុយ យ៉ាងណាមួយពិបាកដូចថាមានគេឈ្នានីសយើងអីចឹងហាស

ក៖ បាទអ៊ូ!ចឹង?

ខ៖
ពិបាកតែគេឈ្នានីសនឹងមីមួយនឹងខ្លាំងជាងគេតែម្ដងយើងធ្វើអីបានចឹងវាអត់នៅទេយើង
ដើរចេញ ចឹងដូចថាយើងដាំត្រកួនវាយកគោវាអោយមកស៊ីត្រកួនយើងអស់ហើយនឹង
ហើយវារករឿងយើងអីទៀត ចឹងទៅណាស់

កៈ  អូ!បាទមីង?

ខៈ  វាលំបាកថាយើងធ្វើអីក៏វារៀងឆ្អៀតចិត្តចឹងទៅណាស់វាមិនស្រួលចិត្តទេ
កាលនៅបិទស្រានឹងវាមិន សូវលំបាកប៉ុន្មានទេនឹង
ដូចថាយើងអត់ទៅដាំដំណាំយើងនៅតែធ្វើនៅផ្ទះនឹងកំប៉េកកំប៉ុកនឹងមិនអីទេ
ពេលដែរយើងចុះទៅធ្វើចំការវាពិបាកណាស់
ពិបាកអីគ្រាន់ថាយើងឡើងមកដាំបាយស៊ីចឹងដល់ពេល
ដែរចុះទៅវិញនឹងគេបំផ្លាញ់ចោលរបស់យើងអីចឹងណាស់

កៈ  បាទមីង?

ខៈ  វាអត់មានអីពិបាកថានេះទេ

កៈ
អូ!ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលសប្បាយនៅក្នុងឆាកជីវិតរបស់មីងដែរ?

ខៈ  អត់ដែរមានសប្បាយចិត្តផងនឹង មិនទាន់បានសប្បាយចិត្តទេនឹង

កៈ  អូ!អត់ទេណាមីង?

ខៈ  នៅពិបាកចិត្តរហូតនឹងនិយាយរួមទៅមិនដឹងថាពេលណាដែរបានសប្បាយចិត្តទេ

កៈ  អូ!បាទមីង?

ខៈ
វាពិបាកចិត្តពេកកូនវាធំប៉ុន្តែម៉ែឪនឹងវាមិនទាន់មានស្ទីរកអីកើតបានទៀតចឹងទៅណាស់

កៈ  បាទមីងបាទ?

ខៈ
វាដូចថាគ្មានអីរកតទៅមុខទៀតនឹងដូចថាកូននឹងបើវាចេះរកបានទៅរកទៅណាស់បើរកមិនបានទេ មានតែម៉ែនឹងលក់ដីលក់ធ្លីការកូនអីចឹងទៅ

កៈ
បាទមីងចុះមីងគិតថាមីងមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់មីងនឹងចេះលេងឧបករណ៍ភ្លេងទេ មីង?

ខ៖ អត់មានទេ

ក៖ បងប្អូនក៏មិនចេះដែរហោសមីង?

ខ៖ អត់មានផងនឹង

ក៖
ចុះផ្ទះរបស់មីងនឹងមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង
?

ខ៖ យ៉ាងម៉េច?

ក៖ ចង់និយាយថាផ្ទះរបស់មីងមានលក្ខណៈបែបណាថាផ្ទះតូច ធំ ឈើ
ថ្មអីចឹងហាសមានលក្ខណៈបែប ណាដេរមីង?

ខ៖ ផ្ទះនឹងវាមានបីបួនសំរាប់តាំងពីដាច់អាពតនឹងមកវាបីភ្លើងហើយណាស់

ក៖ បាទមីង?

ខ៖ ផ្ទះទីមួយនឹងទាប
ទាបនឹងទាបមែនទេយើងធ្វើកំពស់នឹងចឹងហាសយើងនៅយើងនៅចឹងទៅយើងធ្វើ
មួយទៀតធ្វើមួយទៀតនឹងនេះប៉ុនផ្ទះនេះហើយលក់អោយគេមួយទៀតនឹងក៏ទិញមួយទៀ
តមកធ្វើនៅនឹង

ក៖ ល្មមបានផ្ទះប៉ុណ្ណឹងហោសមីង?

ខ៖ ល្មមបានប៉ុននេះនឹងធ្វើលក់អស់បីដងហើយនឹង

ក៖ ចុះមីងធ្វើនឹងមាននរណាគេជាអ្នកធ្វើរឺមួយក៏មីងជួលគេធ្វើអោយដែរមីង?

ខ៖ ជួលគេធ្វើ

ក៖ ចឹងមីងជួលគេធ្វើណាមីង?

ខ៖ ធ្វើមុនៗនឹងម្ដាយគាត់ជាអ្នកធ្វើណាស់

ក៖ បាទមីងបាទ?

ខ៖  ដល់ពេលដែរយើងប្តីចឹងទៅផ្ទះនឹងយើងធ្វើខ្លួនឯងនឹងជួលគេធ្វើទេ

ក៖  អូ៎!បាទមីង?

ខ៖  រកបានទៅយើងជួលគេលើកទេនឹង

ក៖  ចុះមីងគិតថាមីងមានជំនាញអីដែរមីងចេះស្ទាត់ជំនាញ់ទេមីងទាំងការលក់ដូរ ទាំងធ្វើម្ហូបរឺមួយក៏ស្អី ដែរមីងគិតថាមីងចេះស្ទាត់តែម្តងហាស?

ខ៖  វារកចាប់មុខរបរស្ទាត់មិនឃើញសោះនឹងរឿងស្អីក៏ចេះដែរ

ក៖  ប៉ុន្តែអោយស្ទាត់ជំនាញនឹង?

ខ៖  រឿងស្ទាត់ជំនាញនឹងវាមិនស្ទាត់នឹង

ក៖  អូ៎!បាទមីង?

ខ៖  ធ្វើអីក៏បានដែរការីក៏កើត ប្រហើរក៏កើត កកូរក៏កើតដែរ

ក៖ អូ៎!បាទមីង?

ខ៖  ប៉ុន្តែគ្រាន់ថាមុខម្ហូបគេយើងមិនចេះទេយើងអត់ដែរ
ពីព្រោះតែយើងនៅខ្មែរនឹងមិនយើងធ្វើតែ ម្ហូបខ្មែរនឹងមិនចឹងយើងមិនដែរទៅធ្វើម្ហូបគេទេ

ក៖  បាទចុះមីង?

ខ៖ យើងអាចធ្វើកើតនឹង

ក៖
ចុះលក្ខណះថាឪពុកម្តាយរបស់មីងនឹងធ្លាប់បង្រៀនពីជំនាញអីទៅមីងដូចជាកូរស្កត្នោត វេញវល្លិ៍ ធ្វើផ្តៅធ្វើអីផ្សេងៗចឹង?

ខ៖  ធ្វើដែរកូរស្កត្នោតឡើងត្នោតអីចឹងទៅ

ក៖  អូមីងចេះធ្វើដែរណាមីង?

ខ៖  យើងចេះតើ!

ក៖  អូ៎!បាទមីង?

ខ៖ រឿងកញ្ច្រែងល្អីនឹងត្រឹមប៉ាទេចេះហោស ចំណែកកូននឹងមិនចេះ

ក៖ បាទមីង?

ខ៖
ដូចថាវាខ្ចិលធ្វើនៅសម័យនេះវារៀងថោកដែរនឹងដល់ពេលដែរសម័យគេចាយលុយហើយនឹង យើងទិញទៅប៉ុន្តែឪពុកធ្វើនឹងប្រើមិនទាន់អស់ផងនឹង

ក៖ បាទមីង?

ខ៖ ចង្អេអី?

ក៖ បាទមីងចុះមីងចូលចិត្តសារម្ហូបអីគេដែរមីង?

ខ៖ ខ្ញុំចូលចិត្តខ

ក៖ អូ៎!ចូលចិត្តខណាមីង?

ខ៖ ឥឡូវនឹងចូលចិត្តខ ប៉ុន្តែកាលពីនៅក្មេងនឹងម្ហូររាល់តែថ្ងៃនឹង

ក៖ ចុះមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីដែរមីងចូលចិត្តលេងដែរដូចជាចោលឈូង ទាញព្រាត លាក់កន្សែង ដូចស្តេចចង់អីចឹងហាស?

ខ៖ អានឹងទូទៅហើយលេង

ក៖ មីងចូលចិត្តលេងហោសមីង?

ខ៖ នឹងហើយចូលចិត្តលេងនឹងចូលឆ្នាំមិនដែរនៅផ្ទះទេនឹង

ក៖ ទៅវត្តបាត់ៗហើយចឹង?

ខ៖ ទៅវត្តបាត់ៗនឹងទៅសប្បាយហើយមិនដែរនៅផ្ទះទេ

ក៖ មីងចូលចិត្តច្រៀងទេមីង?

ខ៖ ច្រៀងនឹងចូលចិត្តប៉ុន្តែមិនចេះទេ

ក៖ ចឹងមីងមិនចេះច្រៀងទេ?

ខ៖ អត់ចេះច្រៀងទេនឹង

កៈ ប៉ុន្តែមីងចូលចិត្តស្តាប់បទចំរៀងទេ?

ខៈ បទចំរៀងនឹងចូលចិត្ត

កៈ លក្ខណៈបទបុរាណ រឺមួយក៏បទសម័យដែរមីង?

ខៈ លក្ខណៈបទបុរាណនឹង

កៈ
បាទមីងចុះតាំងពីក្មេងនឹងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងមីងចង់ធ្វើអីគេដែរទេមីង?

ខៈ ទេអត់មានសោះនឹង

កៈ អត់មានទេណាមីង?

ខៈ អត់មានទេគ្មានក្តីស្រម៉ៃថាចង់ធ្វើអីទេ

កៈ
ចុះបើសិនជាចង់អោយមីងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើមីងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរមីង?

ខៈ ចង់ផ្តែផ្តាំចង់អោយកូនប្រឹងរៀនសូត្រ
ប្រឹងធ្វើការចេះគ្រប់មុខកុំអោយវាល្ងិតល្ងង់ចឹងហាស

កៈ បាទមីង?

ខៈ ចង់អោយវាចេះគ្រប់មុខអីចឹងទៅស្អីក៏ចេះដែរនឹងហាស

កៈ
បាទចុះបើសិនជាចង់អោយកូនចៅជៀសវៀងវិញតើមីងចង់អោយកូនចៅជៀសវៀងអីគេដែរមីង?

ខៈ ជៀសវៀងបៀរ អាប៉ោង ផឹកស្រា ជក់បារី

កៈ ជក់គ្រឿងញៀនជក់អីចឹងហោសមីង?

ខៈ អោយចោលទាំងអស់

ក៖  នឹងអ្វីដែរមីងចង់អោយជៀសវៀងណាមីង?

ខ៖  នឹងហើយ

ក៖  មានអីដែរមីងចង់ផ្ដែផ្ដាំទៀតអត់មីង?

ខ៖  ផ្ដែផ្ដាំប្អូនៗជំនាន់ក្រោយនឹង
កូនចៅជំនាន់ក្រោយៗនឹងកុំអោយធ្វើអំពើបែបចោកទាបទៀតដូចសព្វ ថ្ងៃនឹងណាស់
ថោកទាបណាស់រាល់ថ្ងៃនឹងថោកទាបណាស់រាល់ថ្ងៃនឹង
ថោកទាបអីដូចថាអ្នករកស៊ីរាល់ថ្ងៃនឹងណាស់

ក៖  បាទមីង?

ខ៖  អ្នកខុសបែរជាត្រូវឯអ្នកត្រូវទៅជាខុស

ក៖  អូ!ចង់និយាយចឹងហោសមីង?

ខ៖  នឹងខ្ញុំចង់និយាយចឹងចង់បានថាបើមនុស្សណុងអាក្រក់ហើយអោយអាក្រក់តែម្ដងទៅ
កុំអោយមនុស្សអាក្រក់នឹងអោយវាទៅជាល្អវិញនឹងវាមិនយកទេវាស្អប់នឹង

ក៖  បាទមីង?

ខ៖
ស្អប់អាពូជនឹងហាសនេះនៅជិតផ្ទះនឹងថ្ងៃមុនវៃគេនៅណោះសោះរួចមកចាប់គ្នានៅនេះ
អាមួយអ្នក វៃអាមួយអ្នកចាប់
មកចាប់អ្នកនេះអាវៃគេមិនចាប់ទេមកចាប់អានេះថាវាក្ដៅអើយក្ដៅ

ក៖  បាទមីង?

ខ៖
វាក្ដៅចេះបើថារាល់ថ្ងៃនឹងបើសិនជាពុករលួយកខ្វក់ចឹងអោយជៀសវៀងអោយបាត់ចោល
ទៅ កុំអោយមាននៅហាសចង់បានចឹង

ក៖  មានអីផ្សេងទៀតទេមីង?

ខ៖
បើថាវាអាក្រក់យកវាទៅបាញ់ចោលតែម្ដងទៅនឹងមែនតើនិយាយអាក្រក់ចឹងហាសមនុស្ស
នឹងហាស

ក៖ បាទមីង?

ខ៖ ស្អប់ណាស់

ក៖ មានអីដែរចង់ផ្ដែផ្ដាំផ្សេងពីនឹងទៀតទេមីង?

ខ៖ ផ្ដែផ្ដាំប៉ុណ្ណឹងបានហើយនឹង

ក៖
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានពិភាក្សាដែរទាក់ទងពីប្រវត្តិរបស់មីងចឹងហា
សមីង ចឹងអរគុណច្រើនមីង៕៕៕